**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៥៥...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខណ្ឌ និងលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ជាភាសាអង់គ្លេសសរសេរថា Cambodian Specified Rubber ហៅកាត់ថា CSR ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- បង្កើនគុណភាពនៃការកែច្នៃកៅស៊ូកម្ពុជា
- ផ្តល់ជំនឿទុកចិត្តដល់អតិថិជនជាតិ និងអន្តរជាតិក្នុងពាណិជ្ជកម្មកៅស៊ូ
- លើកស្ទួយគុណភាពកៅស៊ូកម្ពុជានៅលើទីផ្សារអន្តរជាតិ
- ការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- សម្របសម្រួលការធ្វើអាជីវកម្ម ការកែច្នៃ ការនាំចេញ និងការធ្វើឯកភាវូបនីយកម្មយថាប្រភេទកៅស៊ូកម្ពុជា
- ការពារតម្លៃ និងបង្កើនភាពប្រកួតប្រជែងនៃកៅស៊ូកម្ពុជា និង
- បង្កើនចំណូលរដ្ឋលើពន្ធនាំចេញ ឬពន្ធផ្សេងទៀតពាក់ព័ន្ធនឹងបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ។

**មាត្រា ៣.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ ៖

- "កៅស៊ូកែច្នៃ" សំដៅដល់កៅស៊ូស្ងួតដែលកែច្នៃចេញពីទឹកជ័រ និង ជ័រកក
- "យថាប្រភេទកៅស៊ូកម្ពុជា" សំដៅដល់ថ្នាក់គុណភាពនៃកៅស៊ូកែច្នៃដែលត្រូវបានបំប្លែងក្នុងទម្រង់ជាដុំ តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ដូចបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- "កៅស៊ូក្រៅយថាប្រភេទ" សំដៅដល់កៅស៊ូកែច្នៃទម្រង់ជាដុំដែលពុំឋិតក្នុងថ្នាក់គុណភាព នៃបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- "អ្នកកែច្នៃកៅស៊ូ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផលិតកៅស៊ូកែច្នៃ
- "រោងចក្រកែច្នៃកៅស៊ូ" សំដៅដល់កន្លែងផលិតកៅស៊ូកែច្នៃក្នុងទម្រង់ជាដុំ តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

-"អ្នកនាំចេញកៅស៊ូ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំកៅស៊ូកែច្នៃចេញពីព្រះរាជាណាចក្រកម្ពុជា ដោយប្រើស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា

-"វិញ្ញាបនបត្រ" សំដៅដល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋានដែលបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-"មន្ទីរពិសោធន៍មូលដ្ឋាន" សំដៅដល់មន្ទីរពិសោធន៍យថាប្រភេទ ក្រៅពីមន្ទីរពិសោធន៍ជាតិយថាប្រភេទរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងដែលទទួលស្គាល់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-"របាយការណ៍តេស្ត" សំដៅដល់របាយការណ៍ស្តីពីលទ្ធផលនៃការធ្វើតេស្តសម្រាប់ថ្នាក់កៅស៊ូដែលចេញដោយ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬមន្ទីរពិសោធន៍មូលដ្ឋានដែលបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ចចេញវិញ្ញាបនបត្រ

**មាត្រា ៤.-**

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

-ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

-ចេញលិខិតទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋាន

-ចុះបញ្ជីការោងចក្រកែច្នៃកៅស៊ូដែលស្នើសុំវិញ្ញាបនបត្រ និង មន្ទីរពិសោធន៍ដែលស្នើសុំលិខិតទទួលស្គាល់ជាផ្លូវការ

-ចេញវិញ្ញាបនបត្រតាមសំណើរបស់អតិថិជន

-ចេញលិខិតអនុញ្ញាតឱ្យប្រើប្រាស់ ស្លាកសញ្ញាយថាប្រភេទ កៅស៊ូកម្ពុជា

-ចេញសេចក្តីណែនាំបច្ចេកទេសចាំបាច់សម្រាប់ពង្រឹងគុណភាពកៅស៊ូ និងប្រសិទ្ធភាពនៃការកែច្នៃកៅស៊ូដល់អតិថិជន

-កំណត់បទដ្ឋានកៅស៊ូកែច្នៃ តាមបទដ្ឋានអន្តរជាតិនៃទីផ្សារកៅស៊ូ

-ធ្វើការត្រួតពិនិត្យ និង ណែនាំដល់រោងចក្រកែច្នៃកៅស៊ូដែលស្នើសុំវិញ្ញាបនបត្រ

-ធ្វើការត្រួតពិនិត្យ និង ណែនាំដល់មន្ទីរពិសោធន៍មូលដ្ឋាន ដែលស្នើសុំការទទួលស្គាល់ជាផ្លូវការ

-ផ្តល់ឱ្យ ព្យួរ ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ ឬ វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

-ព្យួរ ឬ លុបចោលបញ្ជីការោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋាន និង

-ទំនាក់ទំនង ឬ រាយការណ៍ជូនស្ថាប័នអាណាព្យាបាល ឬ ភ្នាក់ងារពាក់ព័ន្ធអំពីវិញ្ញាបនកម្មយថាប្រភេទកៅស៊ូកម្ពុជា ។

បែបបទ និង នីតិវិធីសម្រាប់ការសុំ និងការផ្តល់វិញ្ញាបនបត្រ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៥.-**

មន្ទីរពិសោធន៍មូលដ្ឋានមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ÷

-ចេញវិញ្ញាបនបត្រជាផ្លូវការស្របតាមអនុក្រឹត្យនេះ .

-ស្នើសុំចុះបញ្ជិកានៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ និង លិខិតទទួលស្គាល់ជាផ្លូវការ

-ស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-ធ្វើការវិភាគដោយផ្ទាល់ ឬ ធ្វើសេវាកម្មវិភាគគុណភាពកៅស៊ូ តាមយថាប្រភេទកៅស៊ូកម្ពុជា ក្រោយពេលបានចុះបញ្ជិការួច និង ទទួលលិខិតទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-គោរពតាម ទទួលយក ឬ កែតម្រូវតាមលក្ខខណ្ឌ និង ការណែនាំរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លើផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ និង ការវិភាគគុណភាពកៅស៊ូ

-ប្រើប្រាស់ស្លាកសញ្ញារបស់ខ្លួនផ្ទាល់ បន្ថែមលើស្លាកសញ្ញាគុណភាពយថាប្រភេទកៅស៊ូកម្ពុជារបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

**មាត្រា ៦.-**

គំរូបញ្ជិកា វិញ្ញាបនបត្រ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង លិខិតទទួលស្គាល់ជាផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចេញកៅស៊ូកែច្នៃជាទម្រង់ដុំ ត្រូវមានវិញ្ញាបនបត្រតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន លើកលែងតែកៅស៊ូដែលនាំចេញមានបរិមាណតិចជាង ៥ (ប្រាំ) គីឡូក្រាម សម្រាប់ធ្វើជាសំណាក ។

អ្នកនាំចេញយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបង្ហាញវិញ្ញាបនបត្រចំពោះអាជ្ញាធរមានសមត្ថកិច្ចដើម្បីត្រួតពិនិត្យ ជាផ្នែកមួយក្នុងសំណុំបែបបទនាំចេញ ។

អ្នកនាំចេញកៅស៊ូក្រៅយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបង្ហាញរបាយការណ៍តេស្តដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ។

**មាត្រា ៨.-**

អ្នកកែច្នៃកៅស៊ូដែលមានបំណងបញ្ជាក់គុណភាពកៅស៊ូ ត្រូវដាក់ពាក្យស្នើសុំទៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

មន្ទីរពិសោធន៍ត្រូវធ្វើតេស្តបច្ចេកទេសសំណាកកៅស៊ូពីអតិថិជន ដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ស្របតាមវិធីវិភាគដែលបានទទួលស្គាល់ មុនពេលចេញវិញ្ញាបនបត្រ ។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្រចំនួន ៥ (ប្រាំ) ច្បាប់ដើម ដែលមានហត្ថលេខានាយកនិងត្រារបស់វិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា ឬនាយកមន្ទីរពិសោធន៍មូលដ្ឋាន ។

ក្នុងករណីដែលលទ្ធផលនៃការធ្វើតេស្តបង្ហាញថា គុណភាពកៅស៊ូមិនចូលក្នុងថ្នាក់ណាមួយនៃបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា មន្ទីរពិសោធន៍ត្រូវជូនដំណឹងនេះទៅអ្នកស្នើសុំ ហើយត្រូវបញ្ជាក់ក្នុងរបាយការណ៍តេស្តជាកៅស៊ូក្រៅថ្នាក់ ។

## ជំពូកទី ៣
## ការទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋានជាផ្លូវការ និង ការត្រួតពិនិត្យរោងចក្រកែច្នៃកៅស៊ូ

**មាត្រា ៩.-**

រាល់មន្ទីរពិសោធន៍យថាប្រភេទកៅស៊ូកម្ពុជា ត្រូវស្នើសុំការទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិចេញវិញ្ញាបនបត្រ និង សិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ។

លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ៣ (បី) ឆ្នាំ លើកលែងតែក្នុងករណីមានការដកហូតវិញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដោយសារមូលហេតុដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ ។

បែបបទ និងនីតិវិធីនៃការផ្តល់លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១០.-**

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានសិទ្ធិធ្វើតេស្តបច្ចេកទេស ធ្វើការត្រួតពិនិត្យ និង វាយតម្លៃលើប្រតិបត្តិការរបស់រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋាន ដើម្បីធានាឱ្យបាននូវអនុលោមភាពរបស់រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍ទាំងនោះទៅនឹងលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់វិញ្ញាបនបត្រ ។

## ជំពូកទី ៤
## ការបង់កម្រៃ

**មាត្រា ១១.-**

រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋានដែលស្នើសុំចុះបញ្ជិកា ស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង ស្នើសុំលិខិតទទួលស្គាល់ជាផ្លូវការនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវបង់កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងកម្រៃទទួលស្គាល់ជាផ្លូវការ ។

អ្នកស្នើសុំវិញ្ញាបនបត្រ ត្រូវបង់កម្រៃសេវាកម្មសម្រាប់ការធ្វើតេស្ត និង ការចេញវិញ្ញាបនបត្រ ។

កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា កម្រៃសេវាកម្មសម្រាប់ការធ្វើតេស្តនិងការចេញវិញ្ញាបនបត្រ កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង កម្រៃទទួលស្គាល់ជាផ្លូវការ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## ការព្យួរ ការដកហូតលិខិតទទួលស្គាល់ជាផ្លូវការ និង ការពិន័យ

**មាត្រា ១២.-**

ក្នុងករណីរោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាផ្លូវការ និង ទទួលសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា បានប្រព្រឹត្តកំហុសឆ្គងក្នុងលក្ខណៈបច្ចេកទេស វិទ្យាស្ថានមានសិទ្ធិសម្រេចព្យួរ ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង បញ្ជិការោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋាន ។

**មាត្រា ១៣.-**

បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូក្នុងទម្រង់ជាដុំ ដោយគ្មានវិញ្ញាបនបត្រ ឬ របាយការណ៍តេស្តចំពោះកៅស៊ូក្រោយថាប្រភេទកៅស៊ូកម្ពុជា ដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៦២ នៃច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ។

**មាត្រា ១៤.-**

ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៦៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ចំពោះ :

១-បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូដោយប្រើស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ... វិញ្ញាបនបត្រចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋាន

២-បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូ ដោយក្លែងគុណភាពឃថាប្រភេទកៅស៊ូកម្ពុជាខុសពីវិញ្ញាបនបត្រ ។

**មាត្រា ១៥.-**

អ្នកឯកទេសក្នុងក្របខ័ណ្ឌនៃមន្ទីរពិសោធន៍មូលដ្ឋាន ឬមន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរបាយការណ៍តេស្តរបស់ខ្លួន ។ ក្នុងករណីមានការឃុបឃិតក្លែងគុណភាពឃថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងៗទៀត ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ